Khmer Story Lovers

— ទីតាំងការិយាល័យក្រុមអ្នកនិពន្ធមាតុភូមិ ផ្ទះលេខ ២៩ ផ្លូវលេខ ២៧៩ ជីឡូត៍លេខ ២៩៨ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល : អ.គឹមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
« មាតុភូមិ »
ភ្នំពេញ
លេខ ២២

ទីបំផុត ប៉ាយវ៉ាន់ផានដកដង្ហើមយ៉ាងវែង ដម្រុះការតានតឹងក្នុងចិត្ត ទើបសួរស៊ីផាន :

-វិជ្ជាគុនកាំបិតនេះ, ឯងហាត់រៀនពីណាមក ?

-បាទ លោកយាយស៊ីបង្ហាត់ខ្ញុំ ។ វិជ្ជានេះពូកែណាស់ មានចំនួនបីស្ទៀត គឺលេសគុនដាវខាងក្រុមក្តីទឹកកកមួយស្ទៀត ។ លោកយាយប្រាប់ថា ស្ទៀតនីមួយៗ សុទ្ធតែសម្រាប់បង្ក្រាបស្ទៀតដាវខាងក្តីទឹកកក ។

ប៉ាយវ៉ាន់ផានគ្រហឹម :

-ហ៊ឹះ ! បង្ក្រាបស្ទៀតគុនដាវក្តីទឹកកកកផង្ហ ? កុំនិយាយហួសហេតុពេក, យាយស៊ីផានណា ?

-យាយស៊ីជាអ្នកផ្តើមបង្កើតក្រុមព្រះអាទិត្យនិងជាគ្រូរបស់ខ្ញុំ ។ ខ្ញុំជាសិស្សច្បងជំនាន់ទីពីរនៃក្រុមព្រះអាទិត្យ ។

សឹងតែមិនទាន់ចប់សំដី, ប៉ាយវ៉ាន់ផានខឹងក្រោធ គំហកដាក់នាយថា :

- បើឯងមិនទឹកនាគ្រុមបក្សបាសទៅកំហ៊ុះ ម៉េចហ៊ានចូលខ្លួនជាសិស្សក្រុមព្រះអាទិត្យស្អីគេនោះទៀត ? ហ៊ឹះ ! ក្រុមព្រះអាទិត្យ ! ក្រុមព្រះអាទិត្យអី ? មិនដែលឮទេ, ក្នុងពិភពគុនគ្មានឈ្មោះក្រុមព្រះអាទិត្យទេ !

ស៊ីផានទៅមិនទាន់យល់ថា ប៉ាយ៉ាន់ផានទឹង ក៏ខំពន្យល់តទៅទៀត៖

- អ្នកគ្រូខ្ញុំប្រាប់ថា កាលណាព្រះអាទិត្យរះបញ្ចេញមក, ទឹកកកនៅលើភ្នំត្រូវតែរលាយ ៗ ហេតុនេះបើសិស្សភ្នំទឹកកកជួបប្រទះនឹងសិស្សក្រុមព្រះអាទិត្យច្បាស់ជា...ច្បាស់ជា.

នាយចង់បន្តទៀតថាច្បាស់ជាលុតជង្គង់សំពះអង្វរហើយ ៗ ប៉ុន្តែទោះល្ងង់ខ្លៅយ៉ាងណាក៏នាយមិនភ្លើលល់ពោលពាក្យបែបនេះចំពោះមុខសិស្សភ្នំទឹកកកដែរ ៗ ប៉ាយ៉ាន់ផានមុខខ្មៅ បែរស្រែកគំហក៖

- បើសិស្សភ្នំទឹកកកប្រទះនឹងក្រុមព្រះអាទិត្យច្បាស់ជាយ៉ាងម៉េចហ៎ ?

ស៊ីផានគ្រវីក្បាល៖

- ពាក្យមួយម៉ាត់នេះនិយាយចេញមកលោកមិនសប្បាយចិត្តទេ ៗ ចំណែករូបខ្ញុំក៏យល់ថាសំដីអ្នកគ្រូមិនសូវល្អស្ដាប់ដែរ ៗ

ច្បាស់ជាចាញ់ចោរមុខ រត់ប្រាសអាយុមែនទេ ?

- បាទ, សំដីអ្នកគ្រូខ្ញុំមានន័យប្រហាក់ប្រហែលនេះមែន ៗ សូមលោកគ្រូប៉ាយកុំខឹងអី. ប្រហែលអ្នកគ្រូខ្ញុំនិយាយលេងទេ, យកជាការមិនបានឡើយ ៗ

ប៉ាយ៉ាន់ផានប្ដូរជើងស្ដាំចង់ស្ដាំ ស្ដាំឈរយូរតែឈើច្រត់ទាប់ទៀត ហើយមកស្ដាប់ស៊ីផានមួយម៉ាត់ៗ គាត់ទ្រាំលែងបានទៀត ព្រោះមានការពិបាកយល់គំនិតក្រុមភ្នំទឹកកកខ្លាំងពេក ក៏រលាស់ដាវស្រែក៖

- បើដូច្នេះសុំសាកស្នៀតគុនប្រយុទ្ធក្រុមព្រះអាទិត្យមើលសិន, តើអាចបង្ក្រាបគុនដាវភ្នំទឹកកកបានដោយវិធីណា ?

គ្រាន់តែលើកដាវរួចម្ដងស្រាប់ គាត់កាប់ចុះទាប់មុខគាត់ឡើងទៀតស្ទើរបុកអាវុធពីដៃ ៗ ប្អូនស្រីគាត់ម្នាក់ឈ្មោះប៉ាវវ៉ាន់យេប្រញាប់ស្ទុះចេញមកជម្លួស៖

- អាចោរត្រកូលស៊ី, ឯងលែងស្គាល់យើងជាគ្រូមាហើយឬ ? សាកល្បងជាមួយយើងសិនមក!

ប៉ាយ៉ាន់ផានចាំមាត់៖

- ប្អូនប៉ាវ, ប្អូនមិន . . . មិន ...

គាត់ចង់ថាប្អូនមិនកើតទេ, ប៉ុន្តែនឹកទាន់ ក្រែងប្អូនអន់ចិត្តក៏ប្រញាប់កែសំដី៖

- ទុកឲ្យបងសាកល្បងទឹងវាមុនសិន ។

ប៉ាយវ៉ាន់ផានកាន់ដាវដៃឆ្វេងស្រែកខ្លាំងៗ:

- អាគ្រូកួលស៊ីចូលមក!

មាណពកំដៃយ៉ាងញាប់:

- ស្នាមនិងជើងលោកសុទ្ធតែរបួសមិនគួរប្រយុទ្ធគ្នាដល់ទៀតទេ ។ ម៉្យាងទៀត... ខ្ញុំពិតជាចាញ់លោកហើយ !

- ហ៊ឺះ ! ឯងមានចិត្តក្លាហានរបៀបនេះហ៊ានប្រមាថក្រុមគុំទឹកកក ដូច្នេះម៉េចឯងមិនហ៊ានសាកល្បងជាមួយយើង ?

ពេលចប់គាត់បញ្ចេញស្នៀតប៉ុប្ផារីកស្គុសស្គាយ ឃើញតែពន្លឺដាវផ្លេកៗសំដៅស៊ីផាន ។ ទោះគាត់កាន់ដាវដៃឆ្វេងក៏មិនអន់ដែរ ។ មាណពសំដែងស្នៀតគុនកាំបិតឈ្មោះបុប្ផារដូវប្រាំង វាយលុកចូលក្នុងចន្លោះដាវប៉ាយវ៉ាន់ផានបានដូចបំណង ។

ប៉ាយវ៉ាន់ផានភ្ញាក់ព្រើត រំលងសំដែងស្នៀតប៉ុប្ផារីកស្គុសស្គាយភ្លាម ហើយបញ្ចេញស្នៀតបទ្មាភ្លឺថ្លាជំនួសវិញជាប្រញាប់ ។ ស៊ីផានសំដែងស្នៀត កាំបិតព្រះអាទិត្យជាបន្ទាន់ ។ ប៉ាយវ៉ាន់ផានភ្ញាក់ជាលើកទីពីរកាលបើឃើញមាណពគ្រវីកាំបិតកញ្ច្រាស់ ចូលចំចន្លោះដាវគាត់យ៉ាងងាយ គាត់ប្រែស្នៀតមួយទៀតជាបន្ទាន់ ។

ស៊ីផានខ្វះការពិសោធន៍ក្នុងគ្រាប្រយុទ្ធគ្នាទើបបើកឱកាសឲ្យប៉ាយវ៉ាន់ផានផ្លាស់ស្នៀតទាន់ ។ អម្បាញ់មិញបើនាយវាយលុកតាមស្នៀតកាំបិតព្រះអាទិត្យតទៅទៀត យ៉ាងហោចណាស់ក៏អាចប្រាប់ប៉ាយវ៉ាន់ផានឲ្យថយក្រោយបីជំហានដែរ , ត្រូវនឹងពេលឈរជើងឈឺស្ពាហើយកាន់ដាវដៃឆ្វេងផងបើថយមិនទាន់នាយកាប់ផ្តួលក្រេងស្រេច ។ ប៉ុន្តែមាណពល្ងង់ខ្លៅឥតស្គាល់ស្ថានការណ៍ប្រយុទ្ធក៏ចេះតែផ្លាស់ស្នៀតតាមដៃគូ ។ ប៉ាយវ៉ាន់ផានខ្មាសខ្លួនឯងក្រហមមុខស្លៅ សិស្សក្រុមគុំទឹកកកទាំងអស់យល់ហេតុដែលកើតកើតភ័យជួសបងរួមគ្រូយ៉ាងខ្លាំង ។

ពីរបីស្នៀតក្រោយមក គាត់ជួបប្រទះគ្រោះថ្នាក់របៀបនេះទៀត ។ ក្បួនគុនកាំបិតរបស់ក្រុមព្រះអាទិត្យសំរាប់បង្ក្រាបគុនដាវរបស់ក្រុមគុំទឹកកកមែន ទោះគាត់គ្រវីដាវលោតទៅខាងណា ហើសរហូតយ៉ាងណា ក៏គេចមិនផុតដែរ ។ ស៊ីផានមានប្រៀបលើប៉ាយវ៉ាន់ផានដោយ

សារតែកាំបិតចាស់ពិល ។ ល្បុករបស់សាមសិបស្នៀត ខាយលើកកាំបិតកក្តោស់សំពត់លើកទ្រូងស្មាប៉ាយវ៉ាន់ជានមួយរំពេច ។

អ្នកក្លាហានត្រកូលប៉ាយ ហោះឡើងពាក់កណ្ដាលខាង ក្នុងបំណងរំលាយស្នៀតវាយលុក ប៉ុន្តែលើកជើងក្បាលឈឺចុកចាប់ក្បាលទៅតល់ប្លុលផ្ដាប់មុខ,.. ដូច្នេះក៏ប្រញាប់ច្រត់ដៃទប់ដីហារ អស់លទ្ធភាពទប់ទល់ឬការពារបានរង់កាំតែមាណាតសំពត់យកប៉ុណ្ណោះ ។ ស៊ីផានដកដៃចេញពោលព្រងើយ :

- ស្នៀតមួយនេះ ខ្ញុំមិនយកជាការទេ ។

ប៉ាយវ៉ាន់ជានបំភើនកម្លាំងស្ទុះក្រោកក្ដែក គិតថា :

ភាគនេះកេចឈ្មោះយើងពិតជាជ្លួមកហើយ. ម្ដេចក៏មិនព្រលែងឲ្យអស់ដៃ ? ស្នៀតនីមួយៗសុទ្ធតែសំដែងដោយខ្ជិល ហាក់មិនទាន់ហាត់រៀនជល់ក៏តែសោះ ។ ប៉ុន្តែទៀតអានេះមិនទាន់ចេះគុនដាវខាងក្រមភ្នំកកកអបងណា, ម្ដេចក៏អាចឈ្មោះយើងពេញបរិបូណ៌ ។ អាស៊ីផាន់យីនេះកាចសាហាវមិនចាញ់បងប្អូនត្រកូលទីងទេ, ក៏មិនដែលលោគយល់នរណា ក៏ដូចក៏គ្មានឥទ្ធិមេត្តាព្រោះសប្រណីសត្វលោកដែរ ។ បើក៏សម្លាប់យើងទៅ,ប្អូនៗទាំងអស់ប្រយុទ្ធជាមួយក៏ឯណាបាន ? ហេតុអ្វីបានជាក៏ចិត្តល្អដកដៃចេញវិញ ? ប្តូយ... ប្តូយៈរប់នៃបនការស៊ុំតួនយី ?

កំពុងតែគិតរិលវល់ការម្នាក់ ប៉ាយវ៉ាន់ជានលើកដៃឡើង យោរដាវបញ្ចេញស្នៀតងើយមើលមេឃក្បាល ។ សិស្សក្នុងតំកកណាចំមាត់គ្រប់គ្នា ព្រោះជាស្នៀតស្រួលបំផុតសម្រាប់បង្រៀនសិស្សដំបូង, មុននឹងហាត់គុនដាវទាំងពិតសប់ពីស្នៀតអ្នកណាក៏ចេះស្នៀតងើយមើលមេឃដែរ ។ តើនឹកជាប់ង៍រូបគ្រូមិនគួរប្រើស្នៀតនេះក្នុងការប្រយុទ្ធដ៏កាចសាហាវជាមួយមាណពទៀយ. ប្រើបានបោរៀបមួនម្នួលចូនវង្វេងស្មារតីទេដឹង ?

ស៊ីផានក្ខាក់ព្រើត ដោយមិនធ្លាប់ឃើញស្នៀតងើយមើលមេឃសោះ ម្ល៉ោះហើយខាងមិនដឹងសំដែងស្នៀតណាតាមក្រោយ ក៏ត្អូញក៏ស្មារតី ហុចឱកាសឲ្យប៉ាយវ៉ាន់ជានវាត់ដាវវៀនស្មើរ ដូចផ្គរបន្ទរបាក់ដើមទ្រូងមួយរំពេច ។ អ្នកការបានទិសឧត្តរ សំហាក :

- ម៉េចហើយ ! ហាស ៗ ...

ស៊ីផានស្ងួ

-អញ្ចាញមិញជាស្នៀតអីទៅ, ខ្ញុំមិនដែលឃើញសោះ ។

ប៉ាយវ៉ាន់ផានលបសរសើរទឹកចិត្តអង់អាចរបស់មាណពដែលត្រូវចុងដាវចុចកណ្ដាលទ្រូងហើយនៅហ៊ានហាមាត់សួររកឈ្មោះស្មៀនដាវគាត់ទៀត ។

-ឯងពិតជាមិនដែលឃើញខែខឬ?

ស៊ឹផានគ្រវីក្បាល ។ ប៉ាយវ៉ាន់ផានពោល:

- ពេលនេះបើយើងចង់យកជីវិតឯង គឺងាយដូចគេក្រឡាស់បាតដៃ ឬ ដូចក្មេងបកចេក, ប៉ុន្តែយើងជាកូនប្រុស ត្រូវចេះវែកញែកគុណនិងទោសឲ្យដាច់ពីគ្នា ។ អម្បាញ់មិញបងប្អូនត្រកូលចិនព្រួតគ្នាវាយលុកយើង ឯងចេញជួយរំដោះយើងចាកផុតពីគ្រោះថ្នាក់ ។ ឥឡូវជីវិតមួយសងជីវិតមួយ យើងឥតជំពាក់គុណគ្នាទៅវិញទៅមកទេ ។ ចាប់ពីថ្ងៃនេះទៅឯងកុំប្រើសំដីថាគុនកាំបិតក្រុមព្រះអាទិត្យបង្កើតឡើងសម្រាប់បង្ក្រាបគុនដាវក្រុមភ្នំទឹកកកទៀតណា !

ស៊ឹផានង៉ក់ក្បាល ,

-ខ្ញុំបាននិយាយហើយថាខ្ញុំវាយមិនឈ្នះលោកទេ ។ លោកគ្រូប៉ាយ តាមខ្ញុំយល់ស្មៀនអម្បាញ់មិញដូចជាមិនពិបាកទប់ទល់ទេ ។

ពេលចប់នាយផតទ្រូងគ្រវាសកាំបិតកញ្ជាស់លាន់ផាំង! ប៉ះផ្លែដាវប៉ាយវ៉ាន់ផានបាក់ជាពីរកំណាត់ ប៉ាយវ៉ាន់ផានខូចទឹកមុខ លូកជើងគ្រឹះដាវមួយទៀតមកកាន់ហើយចាក់រឹប ៗ បីដងកាមៈស្មៀនតមតាវែកហ័សអស្ចារ្យបណ្ដាលឲ្យស៊ឹផានព្រិលភ្នែកមើលលែងឃើញលែងយល់ ។ ក្នុងពេលនាយរលះរលាំងនោះចុងដាវប៉ាយវ៉ាន់ផានរុញប៉ះកដៃនាយបុតកាំបិតកញ្ជាស់ធ្លាក់ដល់ដីឮស្នូរគ្រាំង ក្នុងពេលដដែលចុងដាវបន្តុលចំដើមទ្រូងនាយទៀត ។

ប៉ាយវ៉ាន់ផានរលាស់ដាវជារង្វង់មូល ដោយប្រែកម្លាំងធាតុយ៉ាំងប៊ុនប្រសប់, គាត់ដាច់សាច់កំណាត់អាវនាយមួយដុំមូលប៉ុនមាត់ចានលេចសាច់ទ្រូងមួយក្រវ៉ាត់តែឥតរបួសឡើយ ។ គាត់អង្រួនដាវម្ដងទៀតទើបស៊ឹផានស្រែកអួយ ! ចុនមើលដើមទ្រូងឃើញស្នាមរបួសប្រាំមួយកន្លែងឈាមហូររមៗ

សិស្សភ្នំទឹកកកស្រែកហ៊ោព្រមគ្នា:

- ស្មៀនផ្កាទឹកកកប្រាំមួយជាន់ ! អស្ចារ្យ !...

ប៉ាយវ៉ាន់ផានពោលទាំងញញឹម:

- សូមឯងទៅដំណាក់ក្រុងវិញចុះ ថាថ្ងៃនេះក្រុមភ្នំទឹកកកបានប្រព្រឹត្តមិនគប្បីចំពោះឯងបន្តិចហើយ !

អ្នកក្លាហានទិសឧត្តរពោលបែបនេះព្រោះនឹកថា :

- សូម្បីតែស្បៀងគុនជសាមញ្ញរបស់ភ្នំទឹកកក ក៏វាមិនដែលស្គាល់ផង, តើវាធ្វើពីម្ដេចវាមិនមែនអាស៊ីផុនយី ? ចិត្តគំនិតក៏ប្លែកពីគ្នាទៀត, អាស៊ីផុនយីគ្មានកាយវិការបែបនេះទេ, ទោះអាត្មាអប្រិយនោះកែចិត្តគំនិត ក៏យើងមិនត្រូវសម្លាប់វាដែរ ។ ស្បៀងភ្នំទឹកកកប្រាំមួយជាន់នេះគ្រាន់ជាការខ្មាសគ្នានាំកុំឲ្យព្រហើនជាក់ក្រុមភ្នំទឹកកកទៀតប៉ុណ្ណោះ ។ ស្នាមរបួសទុកគ្រាន់ចំណាំទៅថ្ងៃក្រោយ ។

ប៉ាយវាន់ជានបោះដាវចោល, លើកប្អូនរួមគ្រូពីរនាក់ ដោយអាការៈឈឺចាប់និងអៀនខ្មាសជាខ្លាំងព្រោះគ្មានសមត្ថភាពការពារប្អូនទាំងអស់បានដូចបំណង ។ ប្អូនប្រាំនាក់ស្លាប់ចោលដោយសារស្នាដៃកញ្ចាស់គ្រកូលទីងទាំងពីរ ។ សិស្សភ្នំទឹកកកដែលនៅសល់លើកសាកសពបីលើស្មា យ៉ាងស្រងូតស្រងាត់ ។ ប៉ាយវាន់ជានអត់ទ្រាំពុំបាន បូរទឹកភ្នែករហាម សង្កៀតធ្មេញក្រឹតៗពោលថា :

-អាចោរហោងយុំទ្យទីងមិនហួសបី, មិនហួសប្អូន ! គំនុំឈាមនេះក្រុមភ្នំទឹកកកមិនភ្លេចទេ ។ ត្រូវសងសឹកទាល់តែបាន, សូមឯងកុំឆាប់ស្លាប់ពេក !

ប៉ាយវាន់ជាន បបួលប្អូនរួមគ្រូចាកចេញដំណើរយ៉ាងស្ងាត់ស្ងៀម ឥតរវល់យកចិត្តទុកដាក់នឹងស៊ីផងានទៀយ ។

មាណពយេម្នាក់ឯងមើលឈាមក្រហមស្រស់ៗ ហូរចេញពីស្នាមរបួសកញ្ចាបេត្រូង, មើលដាវកំបាក់និងកាំបិតកញ្ចាស់ ... សត្វខ្លែងហើរក្រវែលកុងពេលពីប្រែកខ្មុំគ ។ បណ្ដាលឲ្យមាណពតប់ប្រមល់ខ្វល់ខ្វាយចិត្តទន់រើសកាំបិតកញ្ចាស់សៀតចង្កេះហើយស្រែកហៅ :

-អាស៊ីអើយអាស៊ី !

នាយកេសំរៀតតល់ពេលើរកមើលអាស៊ីរតែឥតឃើញសោះគិតថា ប្រហែលនាងរត់ទៅរូងភ្នំមុនហើយដឹង ? នាយកេទៅកាន់កន្លែងចាស់ភ្លាម ។ នាយស្រងាកចិត្តម្ដងទៀតដោយនៅទីនោះមិនឃើញស្រមោលអាស៊ីរបុយាយសាវណ្ឌយសោះ មានតែអក្សរក្រវេមក្រវមលើដី ។

មាណពក្មេងឆ្លើយថា ខ្ញុំមិនដឹងជាជូនធិងទៅទៅណា បាត់អស់, នាយមិនចេះភាសាអក្សរម្លេយូនោះ មិនដឹងគេសរសេរថាម៉េចឡើយ គ្រាន់តែយល់ថាគេចាកចេញពីរូងភ្នំចោលនាយហើយ ។

មាណពអផ្សុកតែមួយភ្លែតទេ ព្រោះនាយធ្លាប់រស់ម្នាក់ឯងតាំងពីតូចមក ។ នាយថែកដោយការបិទមុខរបួសតូចៗលើខ្លួននឹកថា :

- ពួកគេទៅអស់ហើយ, យើងក៏មិនត្រូវនៅទីនេះធ្វើអីដែរ គួរទៅរកម៉ាឌិនអាដ្រូស៊ិន ។

នាយសប្បាយចិត្តម្យ៉ាងដោយគ្មាននរណារខាន ក៏សៀតកាំបិតកញ្ចាស់នឹងចង្កេះដើរទៅកាន់មាត់ទន្លេ ។ ទីនោះរលកវាយផ្ទប់ច្រាំងព្រាវៗ ឥតមានស្រមោលទូកមួយសោះ ។ នាយដើរតាមមាត់ទឹកក្រឡឹងមួយជុំនៅតែឥតឃើញកូនទូក ឬ ស្រមោលចុងក្ដោងឯនាយសោះ បានសេចក្ដីថា កោះវៃស្រឡៅតូចរលកខ្លាំងពេកគ្មាននរណាហ៊ានក្រវែលជិតឡើយ ។

ស៊ីវ៉ានឈរលើកោះសញ្ជឹងគិត

យើងត្រូវនៅលើកោះនេះម្នាក់ឯងច្រើនថ្ងៃណាស់ ដើម្បីរង់ចាំមើលក្រែងមានទូកអ្នកណាមកជួយចម្លង ។ បើគានឃើញស្រមោលអ្វីសោះ យើងត្រូវខំហាត់ហែលទឹកមួយមិនទៀតឲ្យចេះស្ទាត់ទើបមិនភ័យព្រួយនៅពេលនេះទម្លាក់ទឹក ។ ដូចជាមិនត្រូវប្រញាប់ចាកចេញពីកោះវៃស្រឡៅនេះទេ ព្រោះតាទីងមិនហួសបី, ទីងមិនហួសបួន, ទីងៗគុងៗ និងលោកគ្រូប៉ាយស៊ុង្គ តែចង់សម្លាប់យើង ។ បើពួនសម្ងំលើកោះវៃស្រឡៅប្រហែលសុខសប្បាយជាង ។

កំពុងតែសញ្ជឹងគិតក្មេងខ្លួននាយក្លូស្បូ ប្រុកតិចខ្សាយមួយលោតចេញពីគុម្ពស្មៅមកជាក ។ ប៉ុន្តែថ្ងៃនេះមាណពមិនផ្ទៃលបង្អាក់ក្លើងធ្វើអ្វីឡើយ បេះតែផ្លែឈើចំអែតតាក្នា លុះឃើញខ្សាយតែមក នាយក្រេកអរណាស់ដកកាំបិតកាប់ដាំង! ខ្សាយរហ័សណាស់ លោតផ្លោះគេចទៅម្ខាង, នាយយារកាំបិតម្តងទៀតកាប់ខ្សាយដាច់ជាពីរកំណាត់ ។ នាយហៀបនឹងរើសខ្សាយទទួលនឹកឃើញភ្លាមថា កាយវិការអម្បាញ់មិញនេះជាស្នៀតព្រានព្រៃកាប់មុសរបស់យាយេស៊ីទេដឹង? មែន! ស្នៀតព្រានព្រៃកាប់មុសមិនមែនសម្រាប់តែទប់ទល់នឹងបង្ក្រាបគុនជារ៉ក្នុងក្នុងតែប៉ុណ្ណោះទេ ថែមទាំងអាចប្រើប្រាស់បានប្រយោជន៍ផ្សេងៗទៀត ។

នាយបន្តគិតអារម្មណ៍តទៅទៀត:

- អម្បាញ់មិញយើងយារកាំបិតកាប់, វាយ ការបន្តិចឃើញបាក់ដូចលោកគ្រូប៉ាយចញ្ចេញ

Khmer Story Lovers



ស្នៀតដាវប្រយុទ្ធជាមួយយើងដែរ ។ បើចន្ទ្រាយមិនចេះយុទ្ធសិល្បៈវាមានផ្លូវតែមួយ គឺលោតគេចខ្លួនយើងវិញ គឺផ្លូវចេះដែរ, កាលណាគេវាយមកយើងត្រូវលោតគេចឬវង គាត់មិនបាច់ដឹងមុនថា ត្រូវប្រើស្នៀតមួយណាទេ ។

មួយជាតិនេះស៊ីផានមិនដែលហាត់យុទ្ធសិល្បៈទេ ហើយមិនដែលបាននរណាបង្ហាត់ត្រឹមត្រូវឡើយ ។ សៃយានទីប៊ុទីងមិនហួសបួន មិនមែនបង្រៀននាយក្នុងគោលបំណងល្អឡើយ ។ ទីងតុងបង្ហាត់នាយឲ្យចេះតាប់ខ្វាំ ដើម្បីដោះខ្លួនពីកណ្ដាប់ដៃតាទីងមិនហួសបី ។ យាយស៊ុសាវឈួយបង្ហាត់នាយ ក្នុងគោលបំណងឲ្យនាយសំដែងស្នៀតគុនកាំបិតរបស់ក្រុមព្រះអាទិត្យ បង្ក្រាបគុនដាវភ្នំទឹកកក យកប្រយោជន៍ផ្ទាល់ខ្លួន ។ គ្មានអ្នកណាពន្យល់ណែនាំនាយឲ្យចេះប្រើកម្លាំងកាយ, ចេះដកដង្ហើម ឬហាត់លោតតាមមូលដ្ឋានសំខាន់នៃរបៀបហាត់រៀនយុទ្ធសិល្បៈដំបូងឡើយ ម៉េះហើយនាយចេះតែក្រាវ១ មាក់ងងរកផ្លូវយល់ម្ដងបន្តិចៗ ។

ព្រោះហេតុហ្នឹងហើយបានជានាយអាចទប់ទល់ជាមួយប៉ាយវ៉ាន់ជានកាល់លើកដែល គេបញ្ចេញស្នៀតកាចសាហាវ, ដល់គេសំដែងស្នៀតងាយស្រួលបំផុត ឈ្មោះងើយមើលមេឃស្រាប់តែលែងដឹងកាត់វង្វេងទប់ល

ពេលនេះនាយយល់ហើយថា មូលដ្ឋានយុទ្ធសិល្បៈស្ថិតនៅត្រង់ការរើស, មិនមែនបង្រៀនស្នៀតមួយទុកប្រឆាំងនឹងស្នៀតមួយទៀតទេ ។

ហេតុអ្វីបានជានាយមិនយល់តាំងពីដើមទី ? ឆ្លើយថាព្រោះនាយមិនចង់ចេះផង, មិនជួបប្រទះគ្រូបាធ្យាយស្រួលបួលផង ។ ទីងតុងក្ដី, ទីងមិនហួសបួនឬយាយស៊ុក្ដី បានបង្រៀននាយឲ្យប្រើស្នៀតបង្ក្រាបគេតែម្ដង ។ កាលយប់មួយជួបអ្នកស្រីវ៉ុនយូក្នុងខ្ទមកញ្ចាស់ នាយឥតបាននិយាយឆ្លើយឆ្លងជាមួយគាត់សោះ, អ្នកស្រីសោត ក៏គ្រាន់តែជួយកែប្រែកម្រង់ឲ្យនាយប្រើគុនដាវប្រឆាំងក្រុមភ្នំទឹកកកឲ្យបានត្រឹមត្រូវប៉ុណ្ណោះ ឥតបានពន្យល់គ្លឹះក្បាច់អំពីរបៀបប្រែប្រួលក្នុងស្នៀតនីមួយៗទេ ។

ពេលនេះស៊ីផានយល់ច្រើន នាយរីករាយសប្បាយណាស់ពីបារណាម្នាក់ឯង

- កាលនៅលើទូកអ្នកគ្រូប្រាប់ឲ្យយើងធ្វើតាមតាទីងមិនហួសបួនគ្រប់ស្នៀត ហេតុនេះហើយបានជាយើងលើកដៃទម្រមេឃតាមគាត់ឥតត្រូវរបួសអ្នកណាសោះ, ដាក់ប្រយុទ្ធបានក្លាយជាស្បែនបាយខ្លុកបាយឡូតៅវិញ ។ បើលោកតាទីងមិនហួសបួនឆ្លៀតពេលនោះវាយដៃមក យើង

មិនដឹងគ្រោះថ្នាក់ទៅហើយ ? កាលនោះទៀតយេនមិនត្រូវលើកដៃប្រមេយតាមគាត់ទេ , ត្រូវត្រូវស
ដៃចុចជីពចរគាត់វិញទើបមានផលផនះ ។

ពេលនេះគុនផាវ គុនកាំបិត , គុនផាល់ប្ដូចាប់ខ្ញុំ ដែលនាំយរបេះដាំនប៉ុន្មានលេចរូបកន្ទោ គួនការបណ៌នាយ ។ មាណពញញឹមចិនពិតពិតដែលទើបគេឃើញ គំលើកដៃត្រូវត្រូវតាមអំពើចិត្ត ឥតប្រាកដស្មៀតណាជាស្មៀតណាឡើយ ។ ប៉ុន្តែកាយវិការទាំងអស់សុទ្ធតែបញ្ចេញកម្លាំងខ្យល់រឹប ៗ ដូចព្យុះសន្សែភព្វោតបក់ស្លឹកឈើជ្រុះពុយ ។ ឯដុំថ្មតូច ៗ កំប៉ុនទៅលើអាកាសដែរ ។ ពេលថ្មធ្លាក់ចុះមកវិញ នាយតែងយារដៃទះប្តូលោតគេច ហាក់ដូចជាធាក់ប្រយុទ្ធមួយអ័ន្ធាំងក្នា ។ នាយសប្បាយមាត់ឯងយូរទៅកាន់តែកកាយ , ដុំថ្មប៉ុនច្រើនឡើង នាយហ័សឡើងលោតគេចផុតទាំងអស់ ។

ពេលនោះព្លួសូរប្រាវ ! មែកឈើមួយត្រូវកម្លាំងដុំថ្មវាយបាក់ជ្រុះមកដី ។ ស៊ីផាននុកដៃចាប់មែកឈើក្រាក់សង្កុំថ្មទៅម្ខាងបាត់ ហើយចិត្តគ្រែកអរម្នាក់ឯងពោលរង្វើថា :

— នេះមនតិស្មៀតផាវដែលលោកគ្រូបាយប្រើដៃធ្វេងអម្បាញ់មិញ ?

នាយរើសកាំបិតកញ្ចាស់មកវិញ ដៃមួយប្រើស្មៀតគុនផាវ ឈ្មោះមែកឈើខ្លាត់ខ្ទង់ ដៃស្ដាំប្រើស្មៀតព្រានព្រៃកាប់គុសខាងរិដ្ឋាគុនកាំបិត ហើយសំដែងស្មៀតផ្ទុយគ្នា សាកមើលព្រួសនិកខ្យល់ខ្លាំងមហិមាសឹងមិនជឿកហ៊ុងកាយផ្ទាល់ ។ កាំបិតកញ្ចាស់វាយទៅត្រូវមែកឈើបាក់ជាពីរកំណាត់ ឯមែកឈើទៅដៃធ្វេងនោះក៏វាយបើកសំបកឈើក្បែរនោះមួយដុំដែរ ។

មាណពហាក់យូរទៅផត់ដៃផត់ការបូណ៌កាន់តែចូលចិត្តយុទ្ធសិល្បៈឡើង ដូចគេចឹបឃើញកំណាប់មាសពេជ្រ ។ នាយដឹងថាលើកោះគ្មានមនុស្សទេ , ទាះបញ្ចេញស្មៀតខុសខាស់ចិនស្បូន គ្រោក៏គ្មាននរណាសើចយំដែរ ។ នាយកាន់កាំបិតដៃម្ខាងមែកឈើដៃម្ខាងត្រីកាន់តែញាប់កាន់តែរហ័ស យូរ ៗ ទៅលែងដឹងថាស្មៀតគុនផាវឬគុនកាំបិតហើយ ចេះតែបញ្ចេញមកតាមចិត្តឃើញ ។

ក្បួនស្មៀតគុនទាំងឡាយសុទ្ធតែបែកចេញពីគំនិតមនុស្ស ហើយនាយគ្រូបទីមួយ ។ ចន្រ្កងហ៊ក្សួនខ្នាតតុកបង្រៀនសិស្សគ្នុណាជាក្រោយទេ ។ ដូច្នេះស៊ីផានដែលមានកម្លាំងកាយសកស្ដម្ភជាមូល-ដ្ឋានស្រាប់កាចចិត្តឃើញប ញ្ចេញកាយវិការប្លែក ៗ បាន ។ បើយោលទៅលើការចេះដឹងថ្មី ៗ នេះ ។ លុះសង្កេតឃើញចំណុចខ្សោយនៃស្មៀតគុនផាវគុនកាំបិតហើយ នាយប៉ះប៉ូវខ្លួនឯង

បង្កើតបានស្នៀតគុនម៉្យាងហៅយ ខាងឆ្វេងជាដាវ, ខាងស្ដាំជាកាំបិត ។

ក្នុងពេលនោះមានស្នៀតគុនដាវខាងក្រុមក្ងោកកខ្វះ, គុនកាំបិតខាងក្រុមព្រះអាទិត្យខ្វះ, យុទ្ធសិល្បៈរើសយានខ្វះ, ទាំងគុនទំនប់មិនហួសបួន, ប៉ុណ្ណឹងមិនរុនយុទ្ធ ។ នាយមិនបានកំណត់ស្នៀតហើយមិនបានគិតឈ្មោះដាក់ទេ ព្រោះគ្មានបំណងបង្កើតយុទ្ធសិល្បៈឬក្រុមបក្សពួកណា, បើទុកយាងណ៍ក្រក៏នាយនឹកមិនឃើញដែរ ព្រោះមិនចេះអក្សរ ។

ស៊ីផានហាត់បន្ថែមម៉ោងកាន់តែកើនឡើងជាលំដាប់ភ្លេចការស្រេកឃ្លានអស់ ទាល់តែពោះក្យូរត្រូវៗ ទើបផ្អាកមួយគ្រាសិន ។

នាយដាក់រកសាច់ទន្សាយទើបស្រងាកចិត្ត ព្រោះនាយជាន់ខ្ទេចខ្ទីអស់ទៅហើយ ។ មាណពទៅបេះផ្លែឈើមកចំអែតពោះ បន្ទាប់មកស៊ីត្រីបបួលមកវិញបានដាំ ។ លុះដើរដល់ត្រើយភ្នំក៏ឃើញស្រះមោលស្អាតទាំងពីរ ត្រូវនឹងយប់ងងឹតដងខ្យល់ចូលក្នុងវូកក៏ប្រុះខ្លួនដេកលង់លក់ទៅ...

ហ្វូងពាកកណ្ដាលអធ្រាត្រស្រាប់តែព្យុះខ្លាំងពីមាត់ព្រាំង ដូចនរណាចាប់ហែកកំណាត់ក្រាស់ ។ សំឡេងពីហាត់រៀនធ្វើកាយរិកាប្រយុទ្ធគ្នាមក នាយមានត្រចៀកពូកែស្ដាប់ឮឆ្ងាយណាស់ៗ នាយស្ទុះក្រោកភ្ញាក់ដើរសំដៅស្ទួរស័ព្ទសម្លេង ។ នៅក្រោមពន្លឺព្រះចន្ទស្រអាប់ និងហ្វូងនាគរាប់រយពាន់ នាយឃើញទូកមួយដ៏អណ្ដែតយោងឡោងជិតមាត់ព្រាំង ។ ស៊ីផានក៏យប់ផ្អុកស្មានថា ទីងមិនហួសបី ឬទីងមិនហួសបួនមករកទៀតហើយ ។ នាយមិនហ៊ានទៅជិតភ្លាមទេ, ខំបង្រួញខ្លួនពួនក្រោយគល់ឈើលួចមើលសិន ។ ព្យុះខ្លាំងមួយទៀតធ្វើឲ្យទូកបើកត្រូវលត់និងខ្យល់គួចហែកដាច់ តែគ្មានឃើញស្រមោលមនុស្សម្នាក់សោះ ។

កាលបើឃើញទូកធំ រកិលចេញពីព្រាំង នាយបែងគិតច្រើនតើងទៅស្រែកសួរ :

- លើទូកមានមនុស្សទេ ?

គ្មានពុទ្ធម្លើយសោះ ។ មាណពខ្ញុំដើងបំ ខ្លោតផ្លាស់ក្បាលទូកភ្លាម, តមើលក្នុងទូកតែក ឃើញអីសោះ, នាយស្រែកសួរទៀត :

- លោក....តា...ទីងមិនហួសបីនៅក្នុងនេ

គ្មានសម្លេងឆ្លើយសោះ ។ នាយប្រុងដើរចូលក្នុងទូកស្រាប់តែជំពប់ជើងនឹងមនុស្សម្នាក់ដេកស្តូកទទឹងផ្លូវ ។ នាយភ្ញាក់ព្រើតគោរព សុំទោស ! ហើយខុនទៅជួយលើកអ្នកនោះ

ទៀត ។ គ្រាន់តែប៉ះភ្លាម នាយព្រឺក្បាលញាក ព្រោះមនុស្សនេះត្រជាក់ស្រឹបដូចទឹកកកក្លាយជាខ្មោចរឹងស្ដូកស្រេប ។ នាយលាន់មាត់យី ! ហើយរាសដៃទៅម្ខាង ប៉ះមនុស្សមួយទៀតត្រជាក់ស្រឹបដូចគ្នា ។

មាណពវារជើងបួនវែកផ្លូវចូលទៅក្រោយទៀត ទាំងភ័យព្រឺក្បាលសំពោង ។ ជើងនាយប៉ះសាកសពត្រជាក់ ១, ដៃនាយប៉ះខ្លួនមនុស្សត្រជាក់ស្រេប ... នៅខាងក្រោយសុទ្ធតែខ្មោច ។ ខ្លះដេកស្លាប់លើគ្រែ, ខ្លះអង្គុយលើកៅអី ..

អ្នកកម្លោះគិតភ័យជាអនេក ស្រែកខ្លាំង ១ :

- នៅក្នុងទូកមានមនុស្សរស់ទេ ?

ដោយអំណាចភ័យពេក នាយស្រែកលេងចេញតែសម្លេងខ្សាវ ១ ... ស្រែកផងរត់រលន់ខ្លោចទាំងទ្រេតទ្រោតផង រហូតដល់កន្សៃទូក ។ នៅទីនោះឃើញខ្មោចបួនដប់រឹងក្រញង់ ក្រោមពន្លឺព្រះចន្ទ ។ មាណពសម្លឹងសៀមភ័យបែកញើស ស្ដាប់ខ្យល់បក់ក្ដោងរហែកផ្លុំ ៗ រីថែមទាំងគុម្ពព្រៃងងឹតតាមជាយកោះ ព្រូ ១ កណ្ដាលរាត្រីស្ងាត់ ប្រៀបដូចសម្រែកខ្មោចព្រាយបិសាច ។ នាយធ្លាប់រស់នៅម្នាក់ឯងតាមព្រៃភ្នំស្ងាត់ជ្រងំមិនខ្លាចអ្វីមែន , តែពេលនេះនាយនៅលើទូកកណ្ដាលហ្វូងខ្មោចជុំវិញសុទ្ធតែងឹក យប់ស្ងាត់ថែមទៀតនរណាទ្រាំបាន ?

កាលបើព្យុះខ្យល់បក់ពោកនាំសម្លេងចម្លែកមកម្ដងៗ នាយភ័យញ័ររំពេះតែរពើលខ្លាចក្រែងខ្មោចទាំងនេះរស់ឡើងវិញស្ទុះមកច្របាច់កនាយ ដូចកាលនៅភូមិ ហូរជាន ជួបខ្មោចនៅ... នាយរំពឹងជ្រើមម្ដង ១ ព្រឺក្បាលសំពោងប្រុងលោតទៅលើកោះវិញ ស្រាប់តែនឹកទៅឃើញទូកធំរសាត់ឆ្ងាយ សណ្ដោតតាមខ្សែទឹកគ្មានផ្លូវឡើងគោករួចទេ ។

នាយស្រែកមួយរំពុះ លែងហ៊ានចូលក្នុងទូកវិញក៏ឈរកៀកទៅខ្សែទូកហើយលោតឡើងលើដំបូលទូកដងក្ដោងដាប់ស្ពឹតអង្គុយចាំព្រឹក ។

កាលបើព្រះអាទិត្យចែងចាំងក្រហមព្រឿងៗមកពីទិសបូព៌ា ទើបសុីផានអន់ភ័យលោតចុះមកកន្សៃទូកពិនិត្យស្ថានការណ៍ ។ មនុស្សដែលស្លាប់ក្នុងទូកធំនេះមានប្រហែលហុកសិបនាក់មើលមួយត្រួសព្រឺក្បាលខាកបែកញើសស្រាក់ ។ ចម្លែកបំផុតត្រង់សាកសពទាំងអស់គ្មានស្លាកស្នាម ឬ ឈាមហូរបន្តិចណាសោះ, មិនដឹងថាគេស្លាប់ដោយប្រការណា ?

នាយថ្កុលក្នុងទូកតម្រង់ទៅក្បាលវិញ ក្រឡេកមើលគ្រប់ទិសទើបឃើញផ្ទាំងស្លាកពីរប៉ុនបាតដៃ បោះនឹងដែកគោលជាប់ផ្ទាំងខាងមុខ ។ លើផ្ទាំងស្លាកនីមួយៗមានរូបមនុស្សសំពើក , មួយជាមនុស្សញញឹមគួរឲ្យស្រឡាញ់មួយទៀតជារូបមនុស្សមុខកាចសាហាវដូចព្រាយបិសាចគួរស្រៀវស្រើប ។ ស៊ីផានជួបហេតុគេចចៀសខ្លួនបែបនេះមិនដឹងធ្វើយ៉ាងណាទេ , នាយឈរសម្លក់សម្លឹងផ្ទាំងស្លាកមួយសន្ទុះនេះតែភ័យភ្ញាក់ផ្អើលផ្លាសកំនុនមុនវិលងើបមើលទៀត ។

នាយមើលសាកសពអ្នកឃើញកាំបិតរុជគ្រប់ដៃ ខ្លះសៀតដាវនឹងចង្កេះខ្លះកាន់កាំបិត សឲ្យយល់ថាគេជាអ្នកគុននិយមមួយក្រុមធ្វើដំណើរតាមទូក ។ នាយពិនិត្យពិច័យម្តងទៀតឃើញខ្មោចទាំងអស់ពាក់អាវមានប៉ាក់រូបកូនក្រពើរុំស្វាបដូចៗគ្នា ។ នាយរឹតតែឆ្ងល់ខ្លាំងឡើងនឹកថា:

- អ្នកគុននិយមទាំងនេះជាសមាជិកក្រុមបក្សណាមួយហើយ ។ ហេតុអីបានជាស្លាប់អតសល់មួយពាក់កណ្តាលផ្លូវដូច្នេះ ? សត្រូវពួកគេខ្លាំងពូកែដល់ណាទៅនេះ ?

ទូកធំនេះតែរសាត់តាមបណ្តោយទឹកឆ្ងាយទៅៗ រហូតដល់ថ្ងៃត្រង់ទើបប្រទះជ្រោយមួយ ។ ខណៈនោះស៊ីផានឃើញទូកពីរជ្រែកទឹកតម្រង់មក ហើយអ្នកកាន់ចង្កូតទូកខាងណោះស្រែកថា:

ឆាប់បត់ក្បាល ! ឆាប់បត់ក្បាល !

ដោយហេតុឥតមានអ្នកកាន់ចង្កូត ទើបទូកនេះចេះតែរសាត់ទៅប៉ះទឹកគួចខ្លាំង គឺវិលក្បាលខ្លួនឯងយ៉ាងផ្លូវប្រយ៉ាង ។ ទូកពីរទៀតមកដល់បុកគ្នាត្រាំង ទើរត្រង់នោះតែម្តង ។ សម្រែកមនុស្សខ្ញៀវខ្ញា ផ្អើលឆោឡោឡាយជាមួយពាក្យជេរប្រទេចសព្វបែបយ៉ាង ធ្វើឲ្យស៊ីផានភិតភ័យជាខ្លាំងនឹកថា:

- បុកទូកគេទទេៗ យ៉ាងនេះគេមករករឿងយើងឥឡូវហើយ ! គេហៅប្រកាន់យើងថាសម្លាប់មនុស្សមួយក្រុមនេះទៀតផងក៏មិនដឹង ? គិតយ៉ាងម៉េចទៅ ?

មាណពឥឡូវរហ័សរហួនណាស់ គិតភ្លាមឃើញភ្លាម ។ នាយបើកឃ្លុបទូកចិញ្ចាតផ្ដោតចុះទៅក្នុងយ៉ាងរហ័ស ។ ពេលនោះមនុស្សហក់លោតពីទូកពីរព្រិបៗ មកដល់ទូកធំ តែស្រែកគោក្យាលាន់គគ្រឹកដោយឃើញខ្មោចដេរដាស ។ ខ្លះស្រែកថា:

- ឃី ! ក្រុមព្រៃហោះ ! ម៉េចមកស្លាប់អីចឹង ?

ខ្លះស្រែកទាំងភ័យរន្ធត់ :

– សូម្បីតែនាយក្រុមឈិនតាយានក៏ស្លាប់ដែរ !

ស្រាប់តែសម្លេងមួយស្រែកខ្លាំងពីក្បាលខ្លួកថា:

– គឺ ..គឺ...បញ្ញាមរណៈមកហើយ ....

សម្លេងនេះមិនខ្លាំងប៉ុន្មានទេតែមានភាពញាប់ញ័រផុតឧបមា ។ ភ្លាមនោះមនុស្សទាំងអស់បិទមាត់ស្ងៀមឈឹង, ស្ងាត់ច្រៀប ស៊ីផានតួនក្នុងយ៉ូបមើលមិនឃើញមុខជនទាំងនេះឡើយ តែនាយអាចស្មានបានថា គេកំពុងផ្លូលច្របល់ពេញបន្ទុកហាមាត់និយាយលែងរួចគ្រប់គ្នាហើយ បានជាស្ងាត់ជ្រងំបែបនេះ ។

មួយសន្ទុះធំទើបឮម្នាក់ពោលៈ

–ផល់ឆ្នាំដែលបញ្ញាមរណៈចេញមុខប្រតិបត្តិការទៀតហើយ ។ ហ៊ឺ ! ក្រុមត្រីហោនេះពីដើមធ្លាប់ប្រព្រឹត្តអំពើឃោរឃៅនឹងគ្រប់ជំពូក.

ផងនោះផ្អកផ្អើលធំឈប់និយាយគ ។ សម្លេងមួយទៀតស្រែកស្នូរ:

–លោកបងរ៉ូ, ឮថាបញ្ញាមរណៈតែងអញ្ជើញមនុស្សទៅកាន់. . .កាន់ទីនោះសិនទើបសំរុំសំរះកាត់ក្តីក្រោយឬ ? មិនមែនសម្លាប់នៅចំពោះមុខផ្ទះទេ ។

សម្លេងមួយទៀតឆ្លើយ :

–បើសុខចិត្តទៅតាមសេចក្តីអញ្ជើញពិតប្រាកដមែន ។ តែសភាពការណ៍នេះប្រហែលលោកនាយក្រុមឈិនតាយាន មិនព្រមធ្វើតាមបញ្ជា បែរជាបបួលសហការីប្រឆាំងតបវិញ ទើបសេនាបញ្ញាមរណៈទាំងពីរខឹងក្រោធបែបហ្នឹង ។

បច់សំដីនេះកាលណាគេសម្ងំស្ងៀមម្តងទៀត ។ ស៊ីផាននឹកម្នាក់ឯង

–សាកសពនៅក្នុងខ្លួកទាំងអស់សុទ្ធសឹងជាសមាជិកក្រុមត្រីហោះអ៊ីគេនោះ មានទាំងនាយក្រុមមួយរូបផង ។ អ៊ីយ៉ាវីវរហើយយើង ! តើសេនាបញ្ញាមរណៈទាំងពីរមានទៅរកក្រុមឈានល្អីដែរ?

## វគ្គទី ២២

## សេនាបញ្ញាមរណៈ

នាយខ្វាយខ្វល់ក្នុងចិត្តណាស់គិតតទៅទៀតថា :

-ត្រូវប្រញាប់ទៅកាន់ទីតាំងក្រុមឈានល្អ ជូនដំណឹងអកុសលនេះដល់លោកគ្រូពេទ្យដើម្បីប្រុងប្រៀប ដើរការ ។

នាយទឹកភ្នែកក្រុមឈានល្អព្រោះធ្លាប់កំសត់កម្រមួយរយៈពេលស្ទើររស់ស្ទើរស្លាប់ក្នុងទីបាត់ការក្រុមនោះដោយហេតុការកំណត្រចាំផ្សេងៗម្ល៉ោះហើយនាយយកចិត្តទុកដាក់ដល់សុខទុក្ខ លោកគ្រូពេទ្យនិងសមាជិកទាំងអស់ដែលគោរពស្រឡាញ់នាយដូចនាយក្រុមគេពិតៗ ។ ពេលនេះនាយចាំស្តាប់ការសន្ទនារវាងផងទាំងអស់លើទូកទៀត ក្នុងជនម្នាក់បន្លឺថា:

- លោកបងរ៉ូ ! រឿងនេះប្រហែលគ្មានទាក់ទងនឹងក្រុមយើងទេដឹង ? សេនាបញ្ញាមរណៈតាំងពីរ ក៏មិនមករកក្រុមច្បូកដែកយើងដែរ ។

សម្លេង "លោកបងរ៉ូ" តបថា :

- តាំងពីសេនាបញ្ញាមរណៈចេញមកប្រតិបត្តិការក្នុងពិភពគុនយើងហើយៗ គ្មានក្រុមបក្សមួយណាទៀសរួច ... បានឡើយ ។ ហេតុនេះយើងត្រូវរង់ចាំមើលសំណាងសិន ...

គាត់សញ្ជឹងគិតមួយស្របក់ទើបពោលបន្ត:

-ល្អើយចុះ! ឯងលួចបាត់គ្នាយើងម្នាក់ជូនដំណើរនេះដល់លោកនាយក្រុមយើងជាមុនហើយបបួលបងប្អូនយើងទាំងអស់មកក្នុងទូកនេះវិញ, តែកុំរុករើរឿងក្នុងនេះឲ្យសោះ ។ យើងជិះទូកនេះត្រឡប់ទៅកាន់ភូមិនេសាទយើងវិញសិនព្រោះសេនាបញ្ញាមរណៈ បានសម្លាប់ក្រុមត្រីហោះអស់ហើយប្រហែលមិនត្រូវការដែកនេះម្តងទៀតឡើយ ។

សម្លេងមួយផ្សេងតបដោយរីករាយ :

- ត្រូវណាស់ ! មធ្យោបាយប្រសើរមែន ! សេនាតាំងពីស្មានថាទូកនេះសុទ្ធតែខ្មាំងក្រុមត្រីហោះ គេមិនខ្វល់ពិនិត្យមួងទៀតទេ ។ ចាំខ្ញុំទៅប្រាប់គ្នាយើងឲ្យដឹងការ ។

បន្ទាប់ពីនោះមក ស៊ីផានពួសួរពើងមនុស្សឡើងមកក្នុងទូកនេះកាន់តែច្រើនឡើងដែលគ្នា ព៌ុះ ១ ហាក់ក៏គក័យសម្បើមណាស់ ។ សម្លេងមួយបន្លឺថា:

- ក្រុមច្បូកដែកយើងមិនដែលប្រព្រឹត្តអំពើប្បិតាំងផ្ទុំមិនល្អទាំងណោះទេ, ហេតុនេះសេនាបញ្ញាមរណៈតាំងពីប្រហែលមិនមករកគួកយើងឡើយ !

ផងម្នាក់ទៀតពោលសួរ :

Khmer Story Lovers



- ចុះក្រុមគ្រឹះហោះ ថ្លើមធំហ៊ានធ្វើអ្វីមិនគប្បីជាមួយពួកខាងនោះឬ ! បើតាមខ្ញុំយល់នឹងសន្តិសុខក្នុងរវាងដប់ឆ្នាំនេះ កើតមកពី... មកពី

- លោកបងលី , បើលោកនាយក្រុមយើងសុខចិត្តធ្វើតាមបញ្ជាមរណៈ ដោយអញ្ជើញទៅកាន់ទីនោះវាយ៉ាងម៉េចវិញ ?

ជនឈ្មោះលីធ្វើហ៊ុះ តបថា :

- តែទៅតាមពិតជាគ្មានពេលត្រឡប់វិញទេ ។ ច្រើនឆ្នាំហើយតើ ដែលលោកនាយក្រុមទាំងឡាយសុខចិត្តទៅតាមសេចក្តីអញ្ជើញ, តើមានលោកណាអាចត្រឡប់មកវិញដែរ ? លោកនាយក្រុមរាប់ពាន់ស្រឡាញ់ពួកយើងណាស់ យើងមិនអាចបណ្តោយឲ្យលោកយកជីវិតទៅប្តូរម្នាក់ឯងឡើយ ។

- យើងគួរតែបម្រុងខ្លួនឲ្យផុតមួយគ្រាសិនទៅ ។ ពួកឡើងបានសួតីជួយយកអាសាក្រុមច្បាក់ដែកហើយបានជានាំផ្លូវមកជួបពួកនេះដឹងដើងការមុនដូច្នេះ ។ ចំណែកភូមិគ្រឹះយើងវិញ គ្មានអ្នកណាស្គាល់ទេ កាលបើយើងពួនស្ងាត់ហើយ សេនាបញ្ជាមរណៈមានគ្រឿងទៀតវៃយ៉ាងណាក៏មិនងាយរកឃើញដែរ ។

លោកបងវ៉ូ បន្ត :

- លោកនាយក្រុមខំកសាងភូមិទេសាខសិក្សាប់ប្រើការក្នុងគ្រានេះឯងណា ! ប្រាំបីឆ្នាំមកហើយ មិនដែលមាននរណាហែកចេញផុតបរិវេណភូមិមួយជំហានទេ , អាចចាត់ទុកជាកន្លែងមួយល្អប្រសើរសម្រាប់យើង ។

ខណៈនោះមានសម្លេងប្លែកមួយពោលក្តែង ៗ:

-ក្រុមច្បូកដែចយើងត្រូតត្រាជង់ទន្ទេតឥតខ្លាចញញើតអ្នកណាសោះឡើយ សូម្បីព្រះចៅអធិរាជក៏មិនខ្លបខ្លាចដែរ ម្តេចឡើយគ្រាន់តែឮឈ្មោះសេនាបញ្ជាមរណៈអីគេនោះ យើងក៏យ៉ាបាតដើងសព្រាគរត់ពួនដូចអណ្តើកបូលក្នុងស្នូក ? ទោះតែរួបលើកនេះក៏ពិបាកដែរ, ថ្ងៃក្រោយគេសួរមកយើងយកមុខទៅទុកឯណា ? លុមប្តូរជីវិតជាមួយពួកគេម្តងទៅ, ម៉ិនមែនស្លាប់ទាំងអស់គ្នាទេ !

ជនឈ្មោះវ៉ូត្វើយ :

- ពិតមែនហើយថារបស់ពួកយើងក្នុងពិភពគុនប្រៀបដូច ខ្ទឹមឈាមលើមុខកាំបិត ។ ស្ករមើល !

អ្នកណាដែលឃើញលោកបរិល័រខ្លាចគេម្ដង ៗ...

ពេលមិនទាន់ចប់ផងឮសូរស្រែកអូយ ! បរិយាកាសក្នុងទូកស្ងាត់ស្ងៀម ! រួចឮគ្រាំង..

ស៊ុផានដឹងថាមានទឹកស្រក់លើដៃតក់ៗ នាយលើកដៃមកហិត - ធុំឆ្អាបទើបដឹងថាឈាមមនុស្ស ។ លោហិតស្រក់តក់ៗមិនឈប់ឈរ នាយដឹងច្បាស់ថាគេនៅលើក្បាលនាយ បើដឹងថាមានមនុស្សពួនស្កាត់ការ ពិតជាគេសម្លេះខ្លួនពោលបំបិទមាត់មិនខាន ។ នាយភ័យព្រួចខំសម្ងំស្ងាប់ទៅទៀតឥតហ៊ានគេចពីលោហិតធ្លាក់ហូរទេ ។

បន្ទាប់ពីនោះឮជនឈ្មោះវ៉ិនហាក :

- ឯងយល់ថា មិនគួរសម្លាប់លោកបរិល័រ ឬ "

សម្លេងមួយតបដោយញញ៉ីញញ៉ាំថា :

- ទេ ! ទេ.... លោកបរិល័រនិយាយផ្ដេសផ្ដាសពេកបានជាលោកបងខឹង ។ ប៉ុន្តែ ... គាត់មានចិត្ត ... ស្មោះត្រង់នឹងក្រុមបក្សណាស់ ។

- បានសេចក្ដីថា ឯងមិនពេញចិត្តនឹងអំពើរបស់យើងឬ ?

- មិនមែនទេ...

មិនទាន់ចប់សំដីផងសម្រែកខ្លាចផ្សាលាន់ឡើងទៀត ពិតជា«បងវ៉ូ»សម្លាប់ជននិយាយអម្បាញ់មិញទៀតហើយ ។ ម្ដងនេះឈាមហូរតក់ៗ ខុសពីកន្លែងស៊ុផានពួន... រីលើទូកលែងមានមនុស្សហើបមាត់ដែរព្រោះ«បងវ៉ូ»សម្លាប់អស់ពីរនាក់ភ្លាម ៗ គួរស្រៀវសាច់ណាស់ ។ គាត់ពោលបញ្ជាក់:

- មិនមែនខ្ញុំកាចសាហាវជាមួយបងប្អូនទេ ។ តាមពិតរឿងនេះទាក់ទងដល់អាយុជីវិតពួកយើងកប់ពាន់នាក់ណា ! ឲ្យតែខ្ចរខ្ចាយទៅក្រៅយើងស្គាល់ទោសនារបស់មិត្តខាងត្រីហោះមិនខាន ។ លោកបរិល័រស្មានថាគាត់ក្លាហានអង់អាចណាស់ មិនស្ដាយជីវិតទេ បានជាហ៊ានស្រែកឡូឡាដូច្នេះ ។ ប៉ុន្តែទោះបីយ៉ាងណាក៏គាត់ត្រូវតែគិតដល់ជីវិតកប់ពាន់ដែរ, មិនត្រូវទាញមួសលោកនាយក្រុមនិងពួកយើងទៅស្លាប់ជាមួយទេ ។

ជនទាំងអស់ឆ្លើយបាទ ៗ ព្រមគ្នា ។

(នៅមានត)

តម្កល់ទុកតាមលេខ ៣៣៨ ចុះថ្ងៃទី ៣ ៦ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers